00888637

E264

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 20 / 02 / 2013
ម៉ោង (Time/Heure): 10:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier:

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង

**សាធារណៈ / Public**

ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣

**ជូនចំពោះ÷** **ភាគីនៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **សំណួរបន្ថែមទៅភាគីក្រោយសវនាការថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (ឯកសារ E163/5/1/13)**

១. យោងលើព័ត៌មានដែលអង្គជំនុំជម្រះបានទទួលក្នុងអំឡុងពេលសវនាការលើការបំបែកសំណុំរឿងកាលពីថ្ងៃម្សិលមិញនេះ ភាគីត្រូវបានស្នើសុំឲ្យផ្តល់ព័ត៌មានបន្ថែមដូចខាងក្រោមមកអង្គជំនុំជម្រះក្នុងអំឡុងពេលបន្តសវនាការនៅថ្ងៃស្អែក ។

២. សហព្រះរាជអាជ្ញាត្រូវបានស្នើសុំឲ្យផ្តល់កថាខណ្ឌនានា ដែលខ្លួនយល់ឃើញថាចាំបាច់សម្រាប់ដាក់បន្ថែមទៅលើវិសាលភាពនៃការជំនុំជម្រះ ដើម្បីគាំទ្រការពង្រីកវិសាលភាពណាមួយដែលត្រូវបានស្នើសុំក្រៅពីការជម្លៀសប្រជាជនទៅដំណាក់កាលទី ១ និងទី ២ និងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។ នៅក្នុងឯកសារ E163 របស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានគូសបញ្ជាក់ថាកថាខណ្ឌ ១៩២ ដល់កថាខណ្ឌ ២០៤ និង

00888638

E264

កថាខណ្ឌ ៤១៥ ដល់កថាខណ្ឌ ៤៧៥ នៃដីកាដំណោះស្រាយនៃសំណុំរឿង ០០២ គួរត្រូវបាន ដាក់បន្ថែមនៅក្នុងសំណុំរឿង ០០២/០១ ដើម្បីអាចរួមបញ្ចូលមន្ទីរសន្តិសុខ ស-២១។ តាមការវិភាគផ្ទាល់របស់អង្គជំនុំជម្រះបង្ហាញថា កថាខណ្ឌបន្ថែមមួយចំនួនគួរត្រូវបានដាក់បញ្ចូល ដើម្បីធ្វើឲ្យការពង្រីកវិសាលភាពដែលត្រូវបានស្នើសុំនេះមានភាពស៊ីសង្វាក់គ្នា (ជាពិសេស កថាខណ្ឌ ៩៤៩ ដល់ កថា ខណ្ឌ ៩៧៤ បន្ថែមពីលើកថាខណ្ឌ ១៧៨ ដល់កថាខណ្ឌ ១៩១, កថាខណ្ឌ ២០៧ ដល់កថាខណ្ឌ ២០៩, កថាខណ្ឌ ៩១៦ ដល់កថាខណ្ឌ ៩៣៦ និងកថាខណ្ឌ ៩៧៥ ដល់កថាខណ្ឌ ៩៧៧)។ នៅក្នុងកិច្ចប្រជុំត្រៀមរៀបចំសវនាការកាលពីខែ សីហា ឆ្នាំ ២០១២ កន្លងទៅ សហព្រះរាជអាជ្ញាហាក់ដូចជាបានយល់ស្របថាកថាខណ្ឌបន្ថែមទាំងនេះក៏ គួរត្រូវបានដាក់បន្ថែមផងដែរ បើទោះបីជាការដាក់បន្ថែមកថាខណ្ឌផ្សេងៗ អាចមានផលប៉ះពាល់បន្ថែមគួរឲ្យកត់សម្គាល់ចំពោះ សាក្សីដែលនឹងត្រូវកោះហៅមកស្តាប់សក្ខីកម្ម និងឯកសារនានាពាក់ព័ន្ធនឹងការជំនុំជម្រះក៏ដោយ។ ជាងនេះទៀត ប្រសិនបើសហព្រះរាជអាជ្ញាស្នើសុំដាក់ បន្ថែមបទចោទនានាពាក់ព័ន្ធនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ បន្ទាប់ពីមានការពង្រីកវិសាលភាពដល់មន្ទីរ ស-២១ តាមការស្នើសុំដូចដែលបានលើកកាលពីថ្ងៃ ម្សិលមិញមែននោះ កថាខណ្ឌផ្សេងៗមួយចំនួនទៀតនៃដីកាដំណោះស្រាយ (ដូចជា កថាខណ្ឌ ១៥០ ដល់កថាខណ្ឌ ១៥៥, កថាខណ្ឌ ១៤៨០ ដល់កថាខណ្ឌ ១៤៨៨, កថាខណ្ឌ ១៤៩១ ដល់កថាខណ្ឌ ១៤៩២, កថាខណ្ឌ ១៤៩៨ ដល់កថាខណ្ឌ ១៥១០ និង កថាខណ្ឌ ១៥១៥ ដល់កថាខណ្ឌ ១៥២០) នឹងត្រូវដាក់បន្ថែម ហើយភស្តុតាងបន្ថែមក៏អាចត្រូវបានបង្ហាញផងដែរ ពិសេសទាក់ទងនឹងជម្លោះប្រដាប់អាវុធ និងលក្ខណៈជាអន្តរជាតិនៃជម្លោះប្រដាប់អាវុធនេះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះស្នើសហព្រះរាជអាជ្ញាពិចារណាអំពីព័ត៌មានទាំងនេះ និង ប្រគល់បញ្ជីជាក់លាក់មួយនៃកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលសហព្រះរាជអាជ្ញាមាន បំណងស្នើសុំសម្រាប់ការដាក់បញ្ចូលនេះ។

៣. បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងបាន ទទួលនូវសំណើជាច្រើនពីភាគីនានា ដោយភាគីស្នើសុំឲ្យផ្អាកកិច្ចដំណើរការនីតិវិធីសវនាការ ដេញដោលលើភស្តុតាង ឬក៏ស្នើសុំផ្អាកការកំណត់កាលបរិច្ឆេទនៃសវនាការផ្សេងទៀត។ ភាគីទាំងអស់ត្រូវបានអញ្ជើញឲ្យផ្តល់មតិយោបល់ទាក់ទងទៅនឹងកាលបរិច្ឆេទសវនាការដូចបានស្នើ

00888639

E264

ឡើងខាងក្រោម សម្រាប់សប្តាហ៍បន្តបន្ទាប់ ព្រមទាំងពេលវេលានៃសេចក្តីសម្រេចថ្មីលើការបំបែកកិច្ចដំណើរការនីតិវិធី ដោយយោងទៅតាមការពិចារណាដូចតទៅនេះ៖

i. សុខភាពរបស់ជនជាប់ចោទត្រូវបានអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថាជាកត្តាកំណត់សម្រាប់សេចក្តីសម្រេចណាមួយលើវិសាលភាពនៃការជំនុំជម្រះ ហើយអង្គជំនុំជម្រះតុលាការកំពូលក៏បានយល់ស្របតាមដែរ។ អ្នកជំនាញវេជ្ជសាស្ត្រគ្រោងនឹងផ្តល់សក្ខីកម្មដល់អង្គជំនុំជម្រះនៅពាក់កណ្តាលខែ មីនា ឆ្នាំ ២០១៣ ហើយការវាយតម្លៃរបស់អ្នកជំនាញវេជ្ជសាស្ត្រទាំងនោះអាចប៉ះពាល់ដល់ការសម្រេចលើវិសាលភាពនៃកិច្ចដំណើរការនីតិវិធី។

ii. សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើការបំបែកកិច្ចដំណើរការនីតិវិធីយ៉ាងតិចជាពីរភាសាផ្លូវការ អ.វ.ត.ក ដោយមានសំអាងហេតុជាក់លាក់ដូចដែលបានតម្រូវដោយអង្គជំនុំជម្រះតុលាការកំពូលនោះ ប្រហែលជាត្រូវការពេលវេលាយ៉ាងតិចណាស់ក៏ ពីពីរ ទៅបីសប្តាហ៍ ទៀតដែរ ។

iii. សក្ខីកម្មរបស់អ្នកជំនាញ Philip SHORT ត្រូវបានគ្រោងរៀបចំនៅសប្តាហ៍ក្រោយ ហើយអ្នកជំនាញ Elizabeth BECKER ត្រូវបានគ្រោងជាបឋមនៅសប្តាហ៍បន្ទាប់ទៀត។ លទ្ធភាពមានវត្តមានរបស់លោក Philip SHORT គឺមិនមានច្រើននោះឡើយ ហើយលោកស្រី Elizabeth BECKER ដែលត្រូវបានពន្យាពេលដល់ទៅពីរដងមកហើយនោះ ក៏រិតតែពិបាកក្នុងការលើកពេលវេលាបន្ថែមទៀតណាស់។ ប្រសិនបើអង្គជំនុំជម្រះមិនអាចស្តាប់សក្ខីកម្មរបស់អ្នកជំនាញទាំងនេះទៅតាមកាលបរិច្ឆេទដែលបានកំណត់ក្នុងពេលបច្ចុប្បន្ននេះទេ ប្រហែលជាអង្គជំនុំជម្រះនឹងបាត់បង់នូវឱកាសក្នុងការស្តាប់សក្ខីកម្មរបស់ពួកគាត់ទាំងស្រុងតែម្តង។

iv. តើគួរតែពន្យាពេលស្តាប់សក្ខីកម្មរបស់សាក្សីដែលបានគ្រោងឱ្យមកផ្តល់សក្ខីកម្មមុនពេលមានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើការបំបែកកិច្ចដំណើរការនីតិវិធីដែរឬទេ ឬជាជម្រើសម្យ៉ាងទៀតថាតើសាក្សីអាចផ្តល់សក្ខីកម្មយ៉ាងហោចណាស់ទៅលើវិសាលភាពនៃអង្គហេតុដែលបានកំណត់រួចហើយដោយអង្គជំនុំជម្រះមុនពេលមានមោឃភាពដីកាបំបែកកិច្ចដំណើរការនីតិវិធី ព្រមទាំងសេចក្តីសម្រេចដែលពាក់ព័ន្ធនានាដែរឬទេ? អង្គជំនុំជម្រះស្នើភាគីផ្តល់មតិយោបល់ពាក់ព័ន្ធទៅនឹងបុគ្គលដូច

00888640

E264

ខាងក្រោមនេះ ដែលពួកគាត់គ្រោងនឹងមកផ្តល់សក្ខីកម្មក្នុងពេលឆាប់ៗនេះ ដែលរួមមានអ្នកជំនាញ Philip SHORT, Elizabeth BECKER, សាក្សីដែលមានរហស្សនាម TCW-724, TCW-794, TCW-100 និង TCW-110។

៤. ដើម្បីទទួលបានការវាយតម្លៃដែលសុក្រឹត្យបំផុតអំពីការអូសបន្លាយកិច្ចដំណើរការនីតិវិធីសវនាការដែលអាចមាន ប្រសិនបើមានការឯកភាពទៅតាមសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលមន្ទីរ ស-២១ នោះ អង្គជំនុំជម្រះស្នើសុំឲ្យភាគីពិចារណាលើបញ្ហានានាដូចខាងក្រោម៖

i. សហព្រះរាជអាជ្ញាបានគណនាអំពីពេលវេលា ដែលចាំបាច់ដើម្បីពង្រីកវិសាលភាពនៃសវនាការទៅដល់មន្ទីរ ស-២១ ដែលតម្រូវឲ្យស្តាប់សក្ខីកម្ម ឬស្តាប់សក្ខីកម្មឡើងវិញចំពោះសាក្សីដែលមានចំនួនសរុបមិនលើសពី ០៥ រូប ដែលមានជាអាទិ៍ កាំង ហ្គេកអ៊ាវ, សាក្សីដែលមានរហស្សនាម TCCP-21, TCW-540, TCW-698 និង TCW-232 ដែលត្រូវការពេលវេលាចំនួន ១១ ថ្ងៃសវនាការបន្ថែមទៀត។ សហព្រះរាជអាជ្ញាក៏បានស្នើសុំដាក់ឯកសារចំនួន ២០០ ឯកសារ ដែលទំនងជាតម្រូវឲ្យមានសវនាការលើឯកសារបន្ថែមទៀតផងដែរ។ អង្គជំនុំជម្រះស្នើសហព្រះរាជអាជ្ញាបញ្ជាក់ពីការប៉ាន់ស្មានទាំងនេះ និងជាងនេះទៀតស្នើសហព្រះរាជអាជ្ញាបញ្ជាក់ថាតើសហព្រះរាជអាជ្ញាមានបំណងស្នើសុំដាក់បញ្ចូលមន្ទីរ ស-២៤ (ព្រៃស) ទៅក្នុងសំណើសុំពង្រីកវិសាលភាពនេះដែរឬយ៉ាងណា។

ii. ការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលថា សំណើសុំពង្រីកវិសាលភាពដែលបានធ្វើឡើងនេះ អាចសម្រេចទៅបានបន្ទាប់ពីមានសវនាការមួយរយៈពេលខ្លីនោះ គឺអាស្រ័យទៅលើលទ្ធភាពរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ឬការត្រៀមខ្លួនរបស់ពួកគាត់ដើម្បីលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថាក្នុងរយៈពេល ០២ ខែកន្លងទៅនេះ មានជនជាប់ចោទម្នាក់ ឬលើសពីនេះត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ អង្គជំនុំជម្រះអាចបន្តសវនាការបាន គឺអាស្រ័យដោយជនជាប់ចោទបានលះបង់សិទ្ធិមានវត្តមានពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូចប៉ុណ្ណោះ។ តើក្រុមមេធាវីការពារក្តីអាចបញ្ជាក់បានទេថា តើកូនក្តីរបស់ខ្លួនមានឆន្ទៈបន្តលះបង់សិទ្ធិមានវត្តមានដែរឬទេ នៅពេលដែលជនជាប់ចោទមិន

00888641

E264

អាចចូលរួមកិច្ចដំណើរការនីតិវិធីបាន ហើយនៅពេលដែលបុគ្គលដែលអាចជាសាក្សីខាងលើនឹងត្រូវអង្គជំនុំជម្រះកោះហៅឲ្យមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងមន្ទីរ ស-២១ នោះ?

iii. តើសហព្រះរាជអាជ្ញាអាចបញ្ជាក់បានទេថា តើការគណនាពេលវេលាដែលចាំបាច់សម្រាប់បញ្ចប់ចំណុចអង្គហេតុនៃសវនាការពាក់ព័ន្ធនឹងមន្ទីរ ស-២១ នេះ វាអាស្រ័យទៅលើការទទួលយកប្រតិចារឹកពីសំណុំរឿង ០០១ ដែរឬ យ៉ាងណា? យោងតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការបង្ហាញប្រតិចារឹកពីសវនាការដទៃទៀតនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលេខ E96/7 ក្រុមមេធាវីការពារក្តីត្រូវបានស្នើសុំឲ្យគូសបញ្ជាក់ដែរថាតើខ្លួននឹងជំទាស់ទៅនឹងការទទួលយកប្រតិចារឹកសំណុំរឿង ០០១ ពាក់ព័ន្ធនឹងមន្ទីរ ស-២១ ជាភស្តុតាង ដែរឬទេ? សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើសេចក្តីសន្និដ្ឋានតបត្រង់ចំណុចនេះ។